**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**

**គម្រោងទី២ គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍សម្រាប់កម្ពុជា**

(P177185)

# ផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គម

កំណែលើកទី ២ (កែសម្រួលលើកទី ១)

ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០២១

# ផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គម

១. រាជរដ្ឋាភិបាលកម្ពុជា នឹងអនុវត្តគម្រោងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍ សម្រាប់កម្ពុជាលើកទី ២ (**គម្រោង**) តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ (ក.អ.ជ) ដែលមានការពាក់ព័ន្ធនឹងក្រសួងស្ថាប័នដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តាមរយៈអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍), និងមន្ទីរអភិវឌ្ឍន៍ជនបទក្នុងខេត្តចំនួន ៦ ។ សមាគមអភិវឌ្ឍន៍អន្តរជាតិ (ពីនេះតទៅហៅថា "**សមាគម**") បានយល់ព្រមផ្តល់ហិរញ្ញប្បទានដល់គម្រោងនេះ។

២. រាជរដ្ឋាភិបាលកម្ពុជា នឹងអនុវត្តវិធានការ និងសកម្មភាពផ្សេងៗដែលធ្វើឲ្យ**គម្រោង**ត្រូវបានអនុវត្តដោយអនុលោមតាមស្តង់ដារបរិស្ថាន និងសង្គម។ ផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គមនេះបានកំណត់នូវវិធានការ និងសកម្មភាព, ឯកសារ ឬផែនការនានា, ក៏ដូចជាពេលវេលា ដើម្បីអនុវត្ត។

៣. រាជរដ្ឋាភិបាលកម្ពុជា ក៏នឹងប្រតិបត្តិតាមប្រការនានាដែលមានចែងនៅក្នុងឯកសារបរិស្ថាន និងសង្គម ដែលជាឯកសារតម្រូវនៅក្នុងក្របខណ្ឌបរិស្ថាន និងសង្គមនៃ**សមាគម** ហើយដែលគេសំដៅថាជាផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គម ដូចជាក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម, ក្របខណ្ឌគោលនយោបាយតាំងលំនៅដ្ឋានថ្មី, ក្របខណ្ឌគោលនយោបាយជនជាតិដើមភាគតិច, ផែនការការចូលរួមរបស់អ្នកពាក់ព័ន្ធ, និងពេលវេលាដូចមានបញ្ជាក់នៅក្នុងឯកសារបរិស្ថាន និងសង្គម។

៤. រាជរដ្ឋាភិបាលកម្ពុជា ទទួលខុសត្រូវចំពោះការប្រតិបត្តិតម្រូវការទាំងអស់នៅក្នុងផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គមនេះ ទោះបីជាវិធានការ និងសកម្មភាពជាក់លាក់នានាត្រូវបានអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័ន ឬអង្គភាពដូចមានចែងក្នុងកថាខណ្ឌទី ១ (ខាងលើ)។

៥. ការអនុវត្តវិធានការ និងសកម្មភាពដែលបានកំណត់នៅក្នុងផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គមនេះ នឹងមានការតាមដាន និងរាយការណ៍ជូន**សមាគម**ពីសំណាក់ក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គភាពគ្រប់គ្រងគម្រោងរបស់ក្រសួងនេះ ដូចបានតម្រូវនៅក្នុងផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គម និងលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងហិរញ្ញប្បទាន ហើយ**សមាគម**នឹងតាមដាន និងវាយតម្លៃវឌ្ឍនភាព និងការបញ្ចប់វិធានការ និងសកម្មភាពក្នុងរយៈពេលអនុវត្ត**គម្រោង**។

៦. ដូចបានព្រមព្រៀងគ្នារវាង**សមាគម** និងរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ ផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គមនេះអាននឹងមានការកែសម្រួលពីពេលមួយទៅពេលមួយទៀតក្នុងអំឡុងពេលអនុវត្ត**គម្រោង** ដើម្បីឆ្លុះបញ្ចាំងអំពីការសម្របការគ្រប់គ្រងការផ្លាស់ប្តូរនានា និងកាលៈទេសៈដែលមើលពុំឃើញរបស់**គម្រោង** ឬជាការឆ្លើយតបទៅនឹងការវាយតម្លៃលទ្ធផល**គម្រោង** ដែលបានអនុវត្តស្ថិតក្រោមផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គមនេះ។ ក្នុងកាលៈទេសៈបែបនោះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ នឹងយល់ព្រមទៅនឹងការផ្លាស់ប្តូរជាមួយនឹង**សមាគម** ហើយនឹងធ្វើបច្ចុប្បន្នភាពផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គម ដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្តូរទាំងនោះ។ កិច្ចព្រមព្រៀងស្តីពីការផ្លាស់ប្តូរកែប្រែផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គមនេះ នឹងត្រូវបានកត់ត្រាតាមរយៈការផ្តោះប្តូរលិខិតដែលមានចុះហត្ថលេខារវាង

**សមាគម** និងរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ។ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងផ្សព្វផ្សាយផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គម ដែលបានកែសម្រួលបច្ចុប្បន្នភាពនេះភ្លាម។

៧. នៅពេលដែល**គម្រោង**មានការផ្លាស់ប្តូរ, កាលៈទេសៈមិនព្រៀងទុក, ឬលទ្ធផល**គម្រោង**នៅក្នុងការផ្លាស់ប្តូរនោះមានហានិភ័យ និងជះឥទ្ធិពលលើការអនុវត្ត**គម្រោង** រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទត្រូវផ្តល់ថវិកាបន្ថែមប្រសិនបើចាំបាច់ ដើម្បីអនុវត្តវិធានការ និងសកម្មភាពដោះស្រាយហានិភ័យ និងផលប៉ះពាល់ទាំងនោះ ដែលអាចមានហានិភ័យ និងផលប៉ះពាល់ពាក់ព័ន្ធនឹង**គម្រោង** ដូចជាផលប៉ះពាល់បរិស្ថាន, សុខភាព, និងសុវត្ថិភាព, ការហូរចូលនៃកម្លាំងពលកម្ម, និងអំពើហិង្សាលើយេនឌ័រ។

| វិធានការ និងសកម្មភាព | | ពេលវេលា | ស្ថាប័ន/អាជ្ញាធរទទួលបន្ទុក |
|---|---|---|---|
| **ការតាមដាន និងរាយការណ៍** | | | |
| ក | **ការរាយការណ៍ជាប្រចាំ**<br>ជាផ្នែកមួយនៃការរាយការណ៍គម្រោងជាប្រចាំ និងមានការរៀបចំ និងដាក់របាយការណ៍តាមដានជាប្រចាំអំពីលទ្ធផលបរិស្ថាន, សង្គម, សុខភាព, និងសុវត្ថិភាព (ESHS) របស់គម្រោងជូនសមាគម រួមមានជាអាទិ៍ការអនុវត្តផែនការប្តេជ្ញាចិត្តបរិស្ថាន និងសង្គម (ESCP), ស្ថានភាពនៃការរៀបចំ និងអនុវត្តឯកសារបរិស្ថាន និងសង្គម ដែលតម្រូវនៅក្នុង ESCP, សកម្មភាពចូលរួមរបស់អ្នកពាក់ព័ន្ធ, ដំណើរការនៃយន្តការបណ្តឹងតវ៉ា។ ព័ត៌មានលម្អិតបន្ថែមស្តីពីការតាមដាន និងការរាយការណ៍ នឹងមានផ្តល់ជូនក្នុងឯកសារបរិស្ថាន និងសង្គមគម្រោង ដូចជា ESMF, RPF, IPPF, LMP, SEP, និងផែនការជាក់លាក់តាមទីតាំងនីមួយៗ ។ | ចាប់ពីកាលបរិច្ឆេទប្រសិទ្ធភាពគម្រោង<br>• របាយការណ៍តាមដាន ESHS ផ្ញើក្នុងប្រចាំត្រីមាស ត្រូវដាក់ជូនសមាគមត្រឹមចុងសប្តាហ៍ទីមួយ នៃរយៈពេលរាយការណ៍ពេញមួយវដ្តនៃការអនុវត្តគម្រោង។<br>• របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ | PMU នៃ MRD |
| ខ | **ឧបទ្ទវហេតុ និងគ្រោះថ្នាក់**<br>រៀបចំ និងដំណើរការយន្តការរាយការណ៍អំពីឧបទ្ទវហេតុផ្សេងៗ<br><br>ជូនដំណឹងដល់សមាគមភ្លាមៗនូវឧបទ្ទវហេតុ ឬគ្រោះថ្នាក់នានាពាក់ព័ន្ធនឹងគម្រោង ឬអាចនឹងកើតឡើង, ជះឥទ្ធិពលជាវិជ្ជមានលើបរិស្ថាន, ប៉ះពាល់ដល់សហគម, សាធារណៈជន, ឬកម្មករ រួមទាំងគ្រោះថ្នាក់ចរាចរណ៍លើផ្លូវដែលគម្រោងសាងសង់ និងឧបទ្ទវហេតុផ្សេងទៀតដែលបានកើតឡើងនៅក្នុងទីតាំងសាងសង់របស់គម្រោង ឬពាក់ព័ន្ធនឹងការងារសាងសង់ណាទទួលហិរញ្ញប្បទានពីគម្រោង។<br><br>ផ្តល់នូវព័ត៌មានលម្អិតគ្រប់គ្រាន់អំពីឧបទ្ទវហេតុ ឬគ្រោះថ្នាក់ដោយបញ្ជាក់អំពីការអនុវត្តវិធានការភ្លាមៗ ឬការរៀបចំផែនការ ដើម្បីដោះស្រាយបញ្ហាទាំងនោះ និងព័ត៌មានទាំងឡាយណាដែលក្រុមហ៊ុនម៉ៅការ និងស្ថាប័នត្រួតពិនិត្យបានផ្តល់ជូនឲ្យបានសមរម្យ។ បន្ទាប់មក តាមរយៈការស្នើសុំរបស់ធនាគារពិភពលោក រៀបចំរបាយការណ៍ស្តីពីឧបទ្ទវហេតុ ឬគ្រោះថ្នាក់ដោយស្នើឡើងនូវវិធានការ ដើម្បីបង្ការការកើតឡើងនាពេលខាងមុខ។ | ក្នុងអំឡុងពេលរៀបចំគម្រោង និងបន្ទាប់ពីគម្រោងចូលជាធរមាន។<br><br>ជូនដំណឹងទៅសមាគមក្នុងរយៈពេល ២៤ ម៉ោង និងមិនឲ្យលើសពី ៤៨ ម៉ោង បន្ទាប់ពីបានដឹងថាមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់។<br><br>នឹងមានការផ្តល់ជូនរបាយការណ៍ក្នុងរយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីឧបទ្ទវហេតុ ឬគ្រោះថ្នាក់នោះ។ | PMU នៃ MRD |

| | | | |
|---|---|---|---|
| គ | **របាយការណ៍ប្រចាំខែរបស់ក្រុមហ៊ុនម៉ៅការ និងទីប្រឹក្សា**<br>អង្គភាពគ្រប់គ្រងគម្រោង (PMU) ត្រូវបញ្ជាក់លក្ខខណ្ឌលម្អិតអំពីការរៀបចំ និងការដាក់របាយការណ៍នៅក្នុងកិច្ចសន្យាដែលនឹងត្រូវចុះហត្ថលេខាជាមួយក្រុមហ៊ុនម៉ៅការ និងទីប្រឹក្សារបស់ PMU។<br><br>ក្រុមហ៊ុនម៉ៅការត្រូវរៀបចំ និងដាក់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ESMP (C-ESMP) និង LMP (C-LMP) របស់ក្រុមហ៊ុនទៅកាន់ PMU ដើម្បីពិនិត្យ និងកែសម្រួលមុននឹងចាប់ផ្តើមការសាងសង់។ ទីប្រឹក្សាត្រូវរៀបចំ និងដាក់របាយការណ៍បឋមទៅកាន់ PMU ដើម្បីពិនិត្យ និងកែសម្រួលមុននឹងចាប់ផ្តើមការសាងសង់។<br><br>បន្ទាប់មក ក្រុមហ៊ុនម៉ៅការត្រូវដាក់របាយការណ៍តាមដាន ESHS ប្រចាំខែទៅកាន់ PMU ។ របាយការណ៍ ESHS គួររួមបញ្ចូលសេចក្តីលម្អិតស្តីពីលទ្ធផលបរិស្ថាន និងសង្គមរបស់គម្រោង ធៀបនឹងតម្រូវការមានចែងនៅក្នុង C-ESMP និង C-LMP ។ ស្រដៀងគ្នានេះដែរ ទីប្រឹក្សាត្រួតពិនិត្យការសាងសង់ត្រូវរៀបចំ និងដាក់របាយការណ៍តាមដាន ESHS ប្រចាំខែទៅកាន់ PMU ។<br><br>PMU នឹងផ្តល់របាយការណ៍ខាងលើជាទម្រង់របាយការណ៍បូកសរុបទៅកាន់**សមាគម** រៀងរាល់ត្រីមាស និងទៅតាមការស្នើសុំរបស់**សមាគម** ។ | នឹងមានការរៀបចំរបាយការណ៍វឌ្ឍនភាព និងរបាយការណ៍តាមដាន ESHS ដោយទីប្រឹក្សារបស់ PMU ដើម្បីដាក់ជូន PMU រយៈពេលពេញនៃការអនុវត្តគម្រោង។<br><br>នឹងមានការរៀបចំរបាយការណ៍ ESHS ប្រចាំត្រីមាសដោយ PMU ដើម្បីដាក់ជូនសមាគម រយៈពេលពេញនៃការអនុវត្តគម្រោង។ | ក្រុមហ៊ុនម៉ៅការ និងទីប្រឹក្សារបស់ PMU រួមទាំងទីប្រឹក្សាគាំទ្រការរៀបចំ និងការអនុវត្តលម្អិត, ទីប្រឹក្សាបរិស្ថាន និងសង្គម និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ។ |
| ESS 1: **ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម** | | | |
| ១.១ | **រចនាសម្ព័ន្ធស្ថាប័ន**<br>បង្កើត និងរក្សាពេញមួយវដ្តគម្រោងនៃអង្គភាពគ្រប់គ្រងគម្រោង (PMU) នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីអនុវត្តប្រតិបត្តិគម្រោងប្រចាំថ្ងៃ។ PMU នឹងមានការចាត់តាំងបុគ្គលិកមានគុណវុឌ្ឍិពីនាយកដ្ឋាននានារបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងទីប្រឹក្សាដែលជ្រើសរើសពីខាងក្រៅ ដើម្បីបម្រើការងារជំនាញបច្ចេកទេស ដែលក្រសួងអភិវឌ្ឍន៍ជនបទមិនមាន។ លើសពីនេះ PMU នឹងជួលក្រុមហ៊ុនប្រឹក្សាយោបល់ ដើម្បីតាមដានសកម្មភាពសាងសង់របស់គម្រោង ។ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងធានាថា PMU មានបុគ្គលិកគ្រប់គ្រាន់ និងទាន់ពេលវេលាដើម្បី | បង្កើតឲ្យបានក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីគម្រោងចូលជាធរមាន<br><br>រក្សាឲ្យបានពេញមួយវដ្តនៃការអនុវត្តគម្រោង | PMU |

| | | | |
|---|---|---|---|
| | គ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមប្រកបដោយប្រសិទ្ធភាពក្រោមអនុគម្រោងទាំងអស់។ គេរំពឹងថា PMU នឹងចូលរួម (ដូចមានផ្ចះបញ្ជាំងនៅក្នុង ESMF) ជាមួយទីប្រឹក្សារៀបចំអនុវត្ត និងត្រួតពិនិត្យលម្អិត (DDIS), ទីប្រឹក្សា E&S, និងទីប្រឹក្សាតាមដានសង្គម និងបរិស្ថានឯករាជ (ISEMC) ដើម្បីជួយគាំទ្រការអនុវត្តគម្រោង ។<br><br>ជាពិសេស PMU នឹងតែងតាំងយ៉ាងហោចមន្ត្រីបរិស្ថានម្នាក់, មន្ត្រីសង្គមម្នាក់, និងមន្ត្រី GRM ម្នាក់ ដែលនឹងទទួលខុសត្រូវតាមដានដំណើរការនៃយន្តការដោះស្រាយវិវាទរបស់គម្រោង។<br><br>PMU នឹងវិភាជថវិកាទាន់ពេលវេលា និងគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ ESHS យ៉ាងមានប្រសិទ្ធភាពក្នុងអំឡុងពេលអនុវត្តគម្រោង។ | | |
| ១.២ | **ការវាយតម្លៃបរិស្ថាន និងសង្គម**<br>ក្នុងអំឡុងពេលរៀបចំគម្រោង, ធ្វើបច្ចុប្បន្នភាពតាមការទទួលយកពីសំណាក់សមាគម ឯកសារបរិស្ថាន និងសង្គមៈ<br>• ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF), ដែលរួមមានក្របខណ្ឌគោលនយោបាយតាំងលំនៅដ្ឋានថ្មី (RPF), ក្របខណ្ឌគោលនយោបាយជនជាតិដើមភាគតិច (IPPF), នីតិវិធីគ្រប់គ្រងពលកម្ម (LMP)<br>ក្នុងអំឡុងពេលអនុវត្តគម្រោង, រៀបចំ, ពិគ្រោះយោបល់, ទទួលយក, និងអនុវត្តតាមការទទួលយកពីសំណាក់សមាគម ឯកសារបរិស្ថាន និងសង្គម រួមមានៈ<br>• ផែនការតាំងលំនៅដ្ឋានថ្មី (RP) រៀបចំដោយអនុគម្រោងពាក់ព័ន្ធ<br>• ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) សម្រាប់អនុគម្រោងពាក់ព័ន្ធ<br>• ផែនការជនជាតិដើមភាគតិច រៀបចំដោយអនុគម្រោងពាក់ព័ន្ធ<br>ក្នុងករណីត្រូវអនុវត្តសមាសភាគឆ្លើយតបនឹងគ្រោះអាសន្ន និងវិបត្តិ (CERC) MRD នឹងអនុត្តសៀវភៅណែនាំស្ដីពីការឆ្លើយតបនឹងគ្រោះអាសន្នសម្រាប់ CERC (ដែលនឹងត្រូវដាក់បញ្ចូលក្នុង ESMF) | ធ្វើបច្ចុប្បន្នភាព ដើម្បីពិគ្រោះយោបល់ក្នុងអំឡុងពេលរៀបចំគម្រោង និងមុនពេលមានការវាយតម្លៃគម្រោង។<br><br>រៀបចំ/ធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយកិច្ចពិគ្រោះយោបល់មុននឹងចាប់ផ្ដើមសកម្មភាពសាងសង់ និងការអនុវត្តគម្រោង | PMU<br>GDR |
| ១.៣ | **ការគ្រប់គ្រងឧបករណ៍សម្ភារ** | | |

| | | | |
|---|---|---|---|
| | ការពិនិត្យមើលផ្លូវជនបទ និងអនុគម្រោងសាងសង់ស្ពាន ដែលបានស្នើឡើងអនុលោមទៅតាម ESMF របស់គម្រោង (ដែលរួមមាន RPF, IPPF, LMP)។ បន្ទាប់មករៀបចំ, ពិគ្រោះយោបល់, ទទួលយកយោបល់, និងអនុវត្ត ESMP របស់អនុគម្រោង (ដែលអាចរួមមាន RP និង IPP តាមតែការតម្រូវ) ដោយមានការទទួលយល់ព្រមពីសមាគម ។<br><br>អនុវត្តវិធានការ និងសកម្មភាពចែងនៅក្នុង ESCP ដោយប្រុងប្រយ័ត្ន និងអនុលោមទៅតាមពេលវេលាដូចបានកំណត់ និងពិនិត្យស្ថានភាពនៃការអនុវត្ត ESCP ដែលជាផ្នែកមួយនៃការតាមដាន និងរាយការណ៍។<br><br>ជូនដំណឹងដល់សមាគមភ្លាមៗនូវការផ្លាស់ប្តូរដែលបានស្នើឡើងនានា ចំពោះវិសាលភាព, ការរចនារៀបចំគម្រោង, ការអនុវត្តគម្រោង, ឬប្រតិបត្តិការរបស់គម្រោងដែលអាចនឹងបណ្តាលឲ្យមានការផ្លាស់ប្តូរដោយអវិជ្ជមាននៅក្នុងហានិភ័យ ឬផលប៉ះពាល់បរិស្ថាន ឬសង្គមរបស់គម្រោង ក៏ដូចជាលិខិតូបករណ៍បរិស្ថាន និងសង្គម ដែលបានអនុម័តរួចហើយ។<br><br>ក្នុងស្ថានភាពសមស្រប អនុវត្តការវាយតម្លៃបន្ថែម និងការចូលរួមរបស់អ្នកពាក់ព័ន្ធដោយអនុលោមទៅតាម ESS និងការផ្លាស់ប្តូរដែលបានស្នើឡើង ដើម្បីឲ្យមានការអនុម័តពីសំណាក់សមាគមលើ ESCP និងឧបករណ៍គ្រប់គ្រងពាក់ព័ន្ធនានា ដោយអនុលោមទៅតាមការរកឃើញរបស់ការវាយតម្លៃ និងការពិគ្រោះយោបល់។ ផ្សព្វផ្សាយឯកសារ ESCP ដែលបានធ្វើបច្ចុប្បន្នភាពរួច។<br><br>រៀបចំលក្ខខណ្ឌការងារ (TOR) សម្រាប់សេវាកម្មទីប្រឹក្សា/បុគ្គលពាក់ព័ន្ធនឹងការគ្រប់គ្រង ESHS ដែលរួមមានទីប្រឹក្សាត្រួតពិនិត្យសំណង់, ទីប្រឹក្សា DDIS, ទីប្រឹក្សា IESMC ។ TOR គួរដាក់បញ្ចូលលក្ខខណ្ឌកំណត់នៅក្នុង ESMF (ដែលរួមមាន RPF, IPPF, LMP) និង SEP ។ | ធ្វើបច្ចុប្បន្នភាព, ពិគ្រោះយោបល់, និងផ្សព្វផ្សាយមុននឹងមានការចាប់ផ្តើមឲ្យមានការដាក់ដេញថ្លៃ ក្នុងអំឡុងពេលអនុវត្ត និងថៃទាំគម្រោង | PMU |

| | | | |
|---|---|---|---|
| | ធានាថាក្រុមហ៊ុនម៉ៅការនឹងរៀបចំ, ទទួលយកទៅប្រើប្រាស់, ធ្វើបច្ចុប្បន្នភាពផែនការ C-SMP របស់ខ្លួន និងនីតិវិធី C-LMP ដើម្បីដាក់ជូន PMU ពិនិត្យ និងអនុម័តមុននឹងចាប់ផ្តើមសកម្មភាពសាងសង់នៅក្នុងគម្រោង។ | | |
| ១.៤ | **សមាសភាគឆ្លើយតបនឹងវិបត្តិ និងគ្រោះអាសន្ន**<br>ក្នុងករណីផ្តើមឲ្យមាន CERC (ដូចដែលបានព្រមព្រៀងគ្នារវាង MRD និងសមាគម, MRD នឹងអនុវត្តតាមនីតិវិធីដូចមានចែងក្នុងសៀវភៅណែនាំស្តីពីការឆ្លើយតបនឹងគ្រោះអាសន្ន (ដែលជាផ្នែកមួយនៃ ESMF) | បន្ទាប់ពីមានការផ្តើមអនុវត្ត CERC ភ្លាម ដូចមាននៅក្នុងកិច្ចព្រមព្រៀងរបស់សមាគមន និង MRD | |
| ១.៥ | **ការគ្រប់គ្រងក្រុមហ៊ុនម៉ៅការ**<br>ដាក់បញ្ចូលលក្ខខណ្ឌតម្រូវបរិស្ថាន និងសង្គមពាក់ព័ន្ធទាំងអស់ទៅក្នុង EMPF, RPF, IPPF, LMP, និង SEP របស់គម្រោង រួមទាំងយន្តការដោះស្រាយវិវាទទៅក្នុងលក្ខណៈបច្ចេកទេស ESHS នៃឯកសារលទ្ធកម្ម និងកិច្ចសន្យាការងារជាមួយក្រុមហ៊ុនម៉ៅការ។<br><br>ការជ្រើសរើសក្រុមហ៊ុនម៉ៅការៈ ធានាថាក្រុមហ៊ុនម៉ៅការស្របច្បាប់ និងជាស្ថាប័នដែលអាចទុកចិត្តបាន ហើយអាចអនុលោមទៅតាមលក្ខខណ្ឌតម្រូវបរិស្ថាន និងសង្គមនៃគម្រោងបាន។<br><br>ក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា ធានាថាក្រុមហ៊ុនម៉ៅការគោរពទៅតាមលក្ខណៈបច្ចេកទេស ESHS ដូចមានពិពណ៌នានៅក្នុងកិច្ចសន្យារបស់ខ្លួន។ | ក្នុងអំឡុងពេលរៀបចំឯកសារដេញថ្លៃ និងមុនមានការចុះហត្ថលេខាលើកិច្ចសន្យាប្រឹក្សាយោបល់ សាងសង់ និងថែទាំ។<br><br>ពេញមួយការអនុវត្តរបស់កិច្ចសន្យាប្រឹក្សាយោបល់ សាងសង់ និងថែទាំ។ | PMU |
| | **លិខិតអនុញ្ញាត, លិខិតយល់ព្រម, និងលិខិតផ្តល់សិទ្ធិ**<br>ទទួល ឬជួយឲ្យទទួលបាននូវលិខិតអនុញ្ញាត, លិខិតយល់ព្រម, និងលិខិតផ្តល់សិទ្ធិសមរម្យពីអាជ្ញាធរជាតិពាក់ព័ន្ធដែលអាចតម្រូវឲ្យមានការសម្របសម្រួលការអនុវត្តសកម្មភាពគម្រោង។<br><br>អនុលោមតាម ឬជម្រុញឲ្យអនុលោមតាមលក្ខខណ្ឌផ្សេងៗដែលមានចែងនៅក្នុងលិខិតអនុញ្ញាត, លិខិតយល់ព្រម, និងលិខិតផ្តល់សិទ្ធិ របស់អាជ្ញាធរពាក់ព័ន្ធពេញមួយវដ្តគម្រោង។ | ពេញមួយវដ្តគម្រោង<br><br>ក្នុងអំឡុងពេលរៀបចំឯកសារដេញថ្លៃ និងមុនចាប់ផ្តើមការងារសំណង់ (ដូចជាការពិនិត្យ និងការបោសសំអាតមីន និងគ្រាប់មិនទាន់ផ្ទុះ) | PMU<br><br>ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត |

| ESS 2: លក្ខខណ្ឌពលកម្ម និងការងារ | | | |
|---|---|---|---|
| ២.១ | **នីតិវិធីគ្រប់គ្រងកម្លាំងពលកម្ម**<br>រៀបចំ, យកទៅប្រើប្រាស់, និងអនុវត្តនីតិវិធីគ្រប់គ្រងកម្លាំងពលកម្ម (LMP)<br><br>ធានាថារាល់លក្ខខណ្ឌតម្រូវទាំងអស់មានចែងនៅក្នុង LMP ត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារដេញថ្លៃ ដើម្បីធានាថាគម្រោងនឹងដោះស្រាយហានិភ័យនានាពាក់ព័ន្ធនឹងកម្លាំងពលកម្ម ដែលរួមមានជាអាទិ៍ ការបណ្តុះបណ្តាលកម្មករទាំងអស់អំពី ក) វិធានការសុខភាព និងសុវត្ថិភាពការងារ, ខ) ក្រមសីលធម៌ និងការបង្ការការបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ (SEA), ការបៀតបៀនផ្លូវភេទ, អំពើហិង្សាលើកុមារ (VAC), គ) ការទប់ស្កាត់ពលកម្មកុមារ និងពលកម្មដោយបង្ខំ, ឃ) ការត្រៀមបង្ការ និងឆ្លើយតបនឹងគ្រោះអាសន្ន, ង) យន្តការដោះស្រាយបណ្តឹងតវ៉ាសម្រាប់កម្មករគម្រោង និងជនរងគ្រោះ SEA/SH, ច) ការបណ្តុះបណ្តាលកម្មករអំពីកាមរោគ ដូចជាអេដស៍ និងការទប់ស្កាត់មេរោគកូវីដ១៩។ | បច្ចុប្បន្នភាព និងផ្សព្វផ្សាយមុនការវាយតម្លៃគម្រោង<br><br>អនុវត្តពេញមួយវដ្តគម្រោង | PMU<br><br>ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត |
| ២.២ | **យន្តការដោះស្រាយបណ្តឹងតវ៉ាសម្រាប់កម្មករធ្វើការក្នុងគម្រោង**<br>បង្កើត, រក្សា, និងដំណើរការយន្តការដោះស្រាយបណ្តឹងតវ៉ាសម្រាប់កម្មករធ្វើការក្នុងគម្រោងដូចមានចែងនៅក្នុង LMP ហើយដែលមានសង្គតិភាពជាមួយ ESS2 និង ESS4។ | ផ្សព្វផ្សាយមុនមានការវាយតម្លៃគម្រោង<br><br>ធ្វើបច្ចុប្បន្នភាព, ទទួលយកទៅប្រើប្រាស់, និងអនុវត្តមិនឲ្យយូរជាង ៩០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាន | PMU<br><br>ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត |
| ២.៣ | **វិធានការសុខភាព និងសុវត្ថិភាពការងារ**<br>រៀបចំ, យកទៅអនុវត្ត, និងអនុវត្តវិធានការសុខភាព និងសុវត្ថិភាពការងារដែលជាផ្នែកមួយនៃ ESMF របស់គម្រោង<br><br>ធានាថាទីប្រឹក្សាត្រួតពិនិត្យរបស់ក្រុមហ៊ុនម៉ៅការ និងសំណង់ មានការចាត់តាំងបុគ្គលិកដែលមានគុណវុឌ្ឍិ ដើម្បី | ធ្វើបច្ចុប្បន្នភាព, ទទួលយកទៅប្រើប្រាស់, និងអនុវត្តមិនឲ្យយូរជាង ៩០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាន | PMU<br><br>ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត |

| | | | |
|---|---|---|---|
| | ធានាការអនុវត្តវិធានការសុខភាព និងសុវត្ថិភាពការងារប្រកបដោយប្រសិទ្ធភាព។<br><br>អនុវត្តការបណ្តុះបណ្តាលដល់កម្មករក្នុងគម្រោង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីហានិភ័យមេរោគកូវីដ១៩ និងសុខភាព និងសុវត្ថិភាពការងារ និងលក្ខខណ្ឌនានាដែលមាននៅក្នុង LMP (រួមទាំងក្រមសីលធម៌កម្មករផងដែរ)។ | ពេញមួយវដ្តគម្រោង | |
| **ESS 3: ការសន្សំសំចៃធនធាន និងការបង្ការ និងការគ្រប់គ្រងការបំពុលបរិស្ថាន** | | | |
| ៣.១ | **ផែនការគ្រប់គ្រងកាកសំណល់**<br>អភិវឌ្ឍ, យកទៅប្រើប្រាស់, និងអនុវត្តផែនការគ្រប់គ្រងកាកសំណល់ដូចមានចែងនៅក្នុង ESMP របស់អនុគម្រោងស្ថិតក្រោមសកម្មភាព ១.២ និង ១.៣ ខាងលើ។<br><br>តាមដាន និងត្រួតពិនិត្យក្រុមហ៊ុនម៉ៅការ ដើម្បីធានាថាក្រុមហ៊ុនបានអនុវត្ត/ប្រតិបត្តិតាមលក្ខខណ្ឌនានាមានចែងនៅក្នុងកិច្ចសន្យាសាងសង់ និង ESMP អនុគម្រោង ជាពិសេសការអនុវត្តក្រមសីលធម៌បរិស្ថាន, ក្រមសីលធម៌កម្មករ, និងវិធានការកាត់បន្ថយផលប៉ះពាល់ជាក់លាក់ទៅតាមទីតាំងសំណង់នីមួយៗ ពាក់ព័ន្ធនឹងធូលី និងសម្លេងរំខាន, បង្ការទប់ស្កាត់ការបំពុលទឹក, ការគ្រប់គ្រងកាកសំណល់រឹង និងរាវ, ទប់ស្កាត់សញ្ញាគ្រោះថ្នាក់បរិស្ថាន។ល។ | ពេញមួយវដ្តគម្រោង និងក្នុងអំឡុងពេលស្តារនីតិសម្បទា/ការងារសំណង់ | ក្រុមហ៊ុនម៉ៅការ |
| ៣.២ | **ការសន្សំសំចៃធនធាន និងការបង្ការ និងការគ្រប់គ្រងការបំពុលបរិស្ថាន**<br>អភិវឌ្ឍ និងអនុវត្តវិធានការសន្សំសំចៃធនធាន និងបង្ការការបំពុលបរិស្ថាន ដែលជាផ្នែកមួយនៃ ESMF និង ESMP នៅតាមទីតាំងជាក់ស្តែង។ | ពេញមួយវដ្តគម្រោង | PMU |
| **ESS 4: សុខភាព និងសុវត្ថិភាពសហគមន៍** | | | |
| ៤.១ | **សុវត្ថិភាពចរាចរណ៍ផ្លូវគោក**<br>យកទៅប្រើប្រាស់ និងអនុវត្តវិធានការ និងសកម្មភាព ដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលជាការតម្រូវនៅក្នុង ESMP អនុគម្រោង ផ្អែកលើ ESMF អភិវឌ្ឍឡើងក្រោមសកម្មភាព ១.២ និង ១.៣ ខាងលើ។ | ពេញមួយវដ្តគម្រោង | ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត |
| ៤.២ | **សុខភាព និងសុវត្ថិភាពសហគមន៍** | | |

| | | | |
|---|---|---|---|
| | រៀបចំ, យកទៅប្រើប្រាស់, និងអនុវត្តវិធានការ និងសកម្មភាព ដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ជាក់លាក់ចំពោះសហគមន៍ ដែលកើតចេញមកពីសកម្មភាពគម្រោង រួមមានឥរិយាបថរបស់កម្មករក្រុមហ៊ុនម៉ៅការ, ហានិភ័យនៃការហូរចូលកម្លាំងពលកម្ម, ហានិភ័យនៃការចម្លងជំងឺឆ្លង និងមិនឆ្លង ដូចជាកាមរោគ និងអេដស៍ ដោយសារសកម្មភាពគម្រោង, ឆ្លើយតបទៅនឹងស្ថានភាពគ្រោះអាសន្នដែលរួមមានវិធានការបង្ការទប់ស្កាត់កូវីដ១៩ ដូចមានចែងនៅក្នុង ESMP អនុគម្រោង និងមានការទទួលយល់ព្រមពីសមាគម។<br><br>អនុវត្តវិធានការបង្ការទប់ស្កាត់កូវីដ១៩ ដោយអនុលោមទៅតាមសេចក្តីណែនាំបច្ចុប្បន្នភាពរបស់ក្រសួងសុខាភិបាល និងកំណត់សម្គាល់អន្តរកាលរបស់ធនាគារពិភពលោកស្តីពី "ចំណុចពិចារណាទប់ស្កាត់កូវីដ១៩ ក្នុងគម្រោងសាងសង់" ។ | ពេញមួយវដ្តគម្រោង | PMU |
| ៤.៣ | **ហានិភ័យ SEA, SH, និង VAC**<br>វាយតម្លៃហានិភ័យ SEA/SH/VAC នៅកម្រិតអនុគម្រោង និងរៀបចំ, យកទៅប្រើប្រាស់, និងអនុវត្តផែនការសកម្មភាព SEA/SH តាមការចាំបាច់របស់ ESMP អនុគម្រោង ដោយអនុលោមទៅតាម ESMF របស់គម្រោង។<br>• ដាក់បញ្ចូលក្រមសីលធម៌កម្មករស្តីពី SEA/SH/VAC រួមទាំងការហាមឃាត់ SEA/SH/VAC ចូលទៅក្នុងឯកសារដេញថ្លៃការសាងសង់ និងលក្ខខណ្ឌការងារ TOR នៃគ្រប់សេវាកម្មប្រឹក្សាយោបល់ទាំងអស់។<br>• ធានាថាក្រុមហ៊ុនម៉ៅការផ្តល់នូវការបណ្តុះបណ្តាលចាំបាច់ដល់កម្មករទាំងអស់របស់ខ្លួន អំពីក្រមសីលធម៌ស្តីពី SEA/SH/VAC និងហាមឃាត់ SEA/SH/VAC ចំពោះកម្មករ។<br>• វាយតម្លៃហានិភ័យពាក់ព័ន្ធនឹង SEA/SH/VAC ដែលជាផ្នែកមួយ C-ESMP និង C-LMP ។ នៅពេលចាំបាច់ ពិគ្រោះយោបល់ជាមួយសមាគម និងរៀបចំផែនការសកម្មភាព SEA/SH ។<br>• ធ្វើការជាមួយគ្រឹះស្ថាន/អង្គការមិនមែនរដ្ឋាភិបាលដែលមានគុណវុឌ្ឍិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល/ការលើកកម្ពស់ការយល់ដឹងអំពីអនុគម្រោងនៅសហគមន៍ស្តីពី SEA/SH/VAC ។<br>• ធានាថាសមាជិកសហគមន៍ និងភាគីចាប់អារម្មណ៍នៅក្នុងអនុគម្រោង មានការយល់ដឹងអំពីវត្តមាននៃយន្តការដោះស្រាយបណ្តឹងតវ៉ាគម្រោងចំពោះ SEA/SH និងកិច្ចខិតខំប្រឹងប្រែងរបស់គម្រោងក្នុងការ | ពេញមួយវដ្តគម្រោង | PMU |

| | | | |
|---|---|---|---|
| | បង្ការ និងដោះស្រាយឧបទ្ទវហេតុ SEA/SH ។ | | |
| ESS 5: **ការទិញដី, ការហាមឃាត់លើការប្រើប្រាស់ដីធ្លី, និងការតាំងទីលំនៅដ្ឋានថ្មីដោយស្ម័គ្រចិត្ត** | | | |
| ៥.១ | **ក្របខណ្ឌគោលនយោបាយតាំងទីលំនៅដ្ឋានថ្មី**<br>ក្នុងអំឡុងពេលអនុវត្តគម្រោង, រៀបចំ, ពិគ្រោះយោបល់, យកទៅប្រើប្រាស់, និងអនុវត្តផែនការតាំងទីលំនៅដ្ឋានថ្មីជាក់លាក់តាមទីតាំងតាមការចាំបាច់ ដោយអនុលោមតាមក្របខណ្ឌគោលនយោបាយតាំងទីលំនៅដ្ឋានថ្មីរបស់គម្រោង, ESS5, ច្បាប់ជាតិ។ ការរៀបចំផែនការតាំងទីលំនៅដ្ឋានថ្មីនេះ នឹងត្រូវបន្សុីគ្នាជាមួយ ESMF និងការរកឃើញ ESIA ជាក់លាក់តាមទីតាំងផងដែរ ហើយផែនការតាំងទីលំនៅដ្ឋានថ្មីត្រូវអនុវត្តមុនការអនុវត្តសកម្មភាពពាក់ព័ន្ធផ្សេងៗ ដោយមានការទទួលយល់ព្រមពីសមាគម។ | ផែនការតាំងទីលំនៅដ្ឋានថ្មី សម្រាប់អនុគម្រោងត្រូវបានរៀបចំឡើង និងផ្សព្វផ្សាយឲ្យមានការពិគ្រោះយោបល់ មុននឹងការអនុវត្ត និងចាប់ផ្តើមការងារសំណង់ | MRD<br>PMU និង GDR និងអាជ្ញាធរពាក់ព័ន្ធ |
| ៥.២ | **យន្តការបណ្ដឹងតវ៉ា**<br>ជាផ្នែកមួយនៃក្របខណ្ឌគោលនយោបាយតាំងទីលំនៅដ្ឋានថ្មី (ដែលមានបញ្ជាក់នៅក្នុងផ្នែកទី ៥.១ ខាងលើ) ហើយយន្តការនេះត្រូវបានរៀបចំឡើងនៅក្នុងក្របខណ្ឌគោលនយោបាយតាំងទីលំនៅដ្ឋានថ្មីរបស់គម្រោង ដែលមានការសង្ខេបនៅក្នុង SEP របស់គម្រោង ហើយបានផ្សព្វផ្សាយក្នុងអំឡុងពេលរៀបចំគម្រោង។ ក្នុងអំឡុងពេលអនុវត្តគម្រោង យន្តការដោះស្រាយបណ្ដឹងតវ៉ារបស់គម្រោងនេះ នឹងត្រូវផ្សព្វផ្សាយនៅកម្រិតអនុគម្រោង។ គេនឹងប្រើប្រាស់យន្តការនេះ ដើម្បីដោះស្រាយបណ្ដឹងតវ៉ាពាក់ព័ន្ធនឹងការទិញដី, ការផ្តល់ដោយស្ម័គ្រចិត្ត, សំណង, ការតាំងលំនៅដ្ឋានថ្មី, និងការគាំទ្រស្តារជីវភាពឡើងវិញ ដែលប្រជាជនរងផលប៉ះពាល់ អាចនឹងតវ៉ា។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងរក្សាយន្តការដោះស្រាយបណ្ដឹងតវ៉ានេះ ឲ្យមានដំណើរការប្រកបដោយប្រសិទ្ធភាពក្នុងពេញមួយវដ្តនៃគម្រោង ដូចមានចែងនៅក្នុងក្របខណ្ឌគោលនយោបាយតាំងទីលំនៅដ្ឋានថ្មី។ | មុនចាប់ផ្តើមទិញដី និងតាំងលំនៅដ្ឋានថ្មីនៅកម្រិតអនុគម្រោង និងពេញមួយវដ្តគម្រោង | PMU និង GDR និងអាជ្ញាធរពាក់ព័ន្ធ |
| ESS 6: **ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព** | | | |
| ៦.១ | **ហានិភ័យ និងផលប៉ះពាល់លើជីវចម្រុះ**<br>កំណត់ និងអនុវត្តវិធានការ ដើម្បីដោះស្រាយហានិភ័យ និងផលប៉ះពាល់លើជីវចម្រុះ ដែលជាផ្នែកមួយនៃ ESMF និង ESMP នៅពេលណាដែលបានកំណត់ទីតាំងគម្រោងរួច។ បន្ទាប់មកតាមដាន និងរាយការណ៍អំពីការប្រតិបត្តិតាមលក្ខខណ្ឌ ESF របស់ក្រុមហ៊ុនម៉ៅការ។ | ពេញមួយវដ្តគម្រោង | PMU |

| | | | |
|---|---|---|---|
| | គម្រោងនឹងមិនផ្ដល់ហិរញ្ញប្បទានការកែលម្អផ្លូវថ្នល់ ឬស្ពានណាដែលអាចប៉ះពាល់ដល់ជម្រកសត្វព្រៃធ្ងន់ធ្ងរ ដូចជាដែនជម្រកសត្វព្រៃ និងតំបន់ការពារ ឬអនុគម្រោងណាដែលអាចបង្កឲ្យមានការកាប់បំផ្លាញព្រៃឈើ។ ESMF មានផ្តល់ជាសេចក្តីណែនាំជាក់ស្តែង ដើម្បីពិនិត្យមើលផ្លូវជនបទណាដែលបំពានលើលក្ខខណ្ឌវិនិច្ឆ័យ (លក្ខខណ្ឌវិនិច្ឆ័យដកចេញពីសកម្មភាពគម្រោង), បញ្ជីផ្ទៀងផ្ទាត់ត្រួតពិនិត្យផលប៉ះពាល់, និងការកំណត់ និងត្រៀមរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម នៅពេលបានជ្រើសរើសផ្លូវ និងស្ពានជនបទរួច | | |
| **ESS 7: ជនជាតិដើមភាគតិច/សហគមន៍មូលដ្ឋានប្រពៃណីដែលពុំសូវទទួលបានការគាំទ្រនៅតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិច** | | | |
| ៧.១ | **ក្របខណ្ឌផែនការជនជាតិដើមភាគតិច**<br>បច្ចុប្បន្នភាព, ពិគ្រោះយោបល់, យកទៅប្រើប្រាស់, និងអនុវត្តក្របខណ្ឌផែនការជនជាតិដើមភាគតិច (IPPF) ក៏ដូចជារៀបចំ និងអនុវត្តជនជាតិដើមភាគតិច (IPP) នៅពេលចាំបាច់ ដោយអនុលោមតាម ESS7 របស់ធនាគារពិភពលោក និងដោយមានការទទួលយល់ព្រមពីសមាគម។ | មុនមានការវាយតម្លៃគម្រោងក្នុងអំឡុងពេលរៀបចំគម្រោង<br>នឹងអនុវត្តពេញមួយវដ្តគម្រោងសម្រាប់អនុគម្រោងដែលមានវត្តមានជនជាតិដើមភាគតិចនៅក្នុងតំបន់នោះ | PMU |
| ៧.២ | **យន្តការបណ្តឹងតវ៉ា**<br>បច្ចុប្បន្នភាព, ពិគ្រោះយោបល់, យកទៅប្រើប្រាស់, និងអនុវត្តយន្តការដោះស្រាយបណ្តឹងតវ៉ាសម្រាប់ជនជាតិដើមភាគតិច ដូចមានការតម្រូវនៅក្នុង IPPF។ | មុនការចាប់ផ្តើមសកម្មភាពគម្រោង<br>បន្តរហូតពេញមួយគម្រោង | PMU |
| **ESS 8: បេតិកភណ្ឌវប្បធម៌** | | | |
| ៨.១ | **នីតិវិធីប្រទះឃើញដោយចៃដន្យ**<br>រៀបចំ, យកទៅប្រើប្រាស់, និងអនុវត្តនីតិវិធីប្រទះឃើញដោយចៃដន្យ ដែលជាផ្នែកមួយនៃ ESMF និង ESMP របស់គម្រោង។ | មុនមានការវាយតម្លៃគម្រោងសម្រាប់ ESMF និងមុនមានការចាប់ផ្តើមការងារសំណង់សម្រាប់ ESMP។ នីតិវិធីនេះនឹងត្រូវអនុវត្តពេញមួយវដ្តគម្រោង និង | |

| | | | |
|---|---|---|---|
| | | រយៈពេលថែទាំផ្លូវថ្នល់ | |
| ESS 10: ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មាន | | | |
| ១០.១ | **ការរៀបចំ និងការអនុវត្តផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ**<br>បច្ចុប្បន្នភាព, យកទៅប្រើប្រាស់, និងអនុវត្តផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP) នឹងធានាថា SEP នេះនៅតែអនុញ្ញាតឲ្យក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិចមានលទ្ធភាពទទួលបានពេញមួយវដ្តគម្រោង។ | មុនមានការវាយតម្លៃគម្រោង។ ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាពបើចាំបាច់ក្នុងអំឡុងពេលអនុវត្តគម្រោង | PMU |
| ១០.២ | **យន្តការបណ្តឹងតវ៉ាគម្រោង**<br>បង្កើត, ប្រើប្រាស់, ធានាឲ្យមានយន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោង ដែលមានដំណើរការដូចមានចែងលម្អិតនៅក្នុង RPF, IPPF, និង LMP ហើយដែលមានការសង្ខេបនៅក្នុង SEP របស់គម្រោង។<br><br>បន្ថែមពីលើយន្តការដោះស្រាយបណ្តឹងតវ៉ាជាក់លាក់ ដើម្បីដោះស្រាយបណ្តឹងតវ៉ានានា ធានាថាមានចរន្តផ្សេងៗគ្នាក្នុងការទទួលបណ្តឹងតវ៉ាដែលអាចកើតឡើងក្នុងអំឡុងពេលអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាពខ្ពស់។ ធានាថាជនបង្គោល GRM, ជនបង្គោល GRM របស់ក្រុមហ៊ុនម៉ៅការ, ប្រធានភូមិ, មេដឹកនាំជនជាតិដើមភាគតិចមូលដ្ឋាន និងចរន្តរដ្ឋាភិបាលដែលមានស្រាប់ មានវត្តមាន និងអាចប្រើប្រាស់បានពីសំណាក់អ្នកពាក់ព័ន្ធដែលរងគ្រោះ ដើម្បីទទួលបានការដោះស្រាយបណ្តឹងតវ៉ាទាន់ពេលវេលា និងមានប្រសិទ្ធភាព។ | មុនចាប់ផ្តើមសកម្មភាពគម្រោង អនុវត្តពេញមួយវដ្តគម្រោង | PMU (ចំពោះយន្តការដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការទិញដី, SEA, SH, VAC)។<br>ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត (GRM សម្រាប់កម្មករ) |
| ១០.៣ | **ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មាន**<br>ប្រើប្រាស់វិធានការដែលមានចែងនៅក្នុង ESMF, RPF, IPPF, LMP, និង SEP<br><br>ធានាថាមានការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងគម្រោងដល់ជន ដែលអាចនឹងរងផលប៉ះពាល់ពីគម្រោង និងដល់អ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ មុននឹងមានការពិគ្រោះយោបល់ជាមួយពួកគាត់។ ត្រូវមានការផ្សព្វផ្សាយព័ត៌មានគម្រោងសំខាន់ៗ រួមមានគោលបំណង, សកម្មភាព, វិសាលភាព, និងលក្ខណៈ, ទីតាំង, ហានិភ័យ និងផលប៉ះពាល់របស់គម្រោង (ជាពិសេសនៅកម្រិតអនុគម្រោង), វិធានការកាត់បន្ថយផលប៉ះពាល់, និង GRM របស់ | មុន និងអំឡុងពេលអនុវត្តគម្រោង ជាពិសេសមុនការអនុវត្តនៅកម្រិតអនុគម្រោង | PMU<br><br>ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត |

| | | | |
|---|---|---|---|
| | គម្រោង។ ធានាថាអ្នកពាក់ព័ន្ធទទួលបានព័ត៌មានអំពីគម្រោងទាន់ពេលវេលា និងមុនមានការពិគ្រោះយោបល់ ហើយព័ត៌មានអាចរកបានតាមរយៈចរន្តផ្សេងៗ, មានភាពងាយយល់, ហើយការពិគ្រោះយោបល់ជាមួយពួកគាត់នឹងអនុវត្តឡើងក្នុងបែបបទសក្តិសមទៅនឹងវប្បធម៌ប្រពៃណីរបស់ពួកគាត់។ ការពិគ្រោះយោបល់ គួរពុំមានការបំភ្លៃ, ការជ្រៀតជ្រែក, ការបន្លំ, ការរើសអើង, និងការគំរាមកំហែង។<br><br>ធានាថាជនដែលចូលរួមក្នុងការពិគ្រោះយោបល់ អាចលើកឡើងជាសំណួរ, ក្តីបារម្ភ, និង/ឬបណ្តឹងតវ៉ាដែលខ្លួនអាចនឹងមាន។ | | |
| **ការគាំទ្រសមត្ថភាព (ការបណ្តុះបណ្តាល)** | | | |
| CS1 | ប្តេជ្ញាចិត្តអនុវត្តសកម្មភាពកសាងសមត្ថភាព ដែលបានកំណត់នៅក្នុង ESMF (ផ្នែក ៧.៣.២៖ ការកសាងសមត្ថភាព)។ ស្របនឹងចំណុចនេះដែរ នឹងមានការផ្តល់វគ្គបណ្តុះបណ្តាលសំខាន់ៗមួយចំនួន និងវគ្គដដែលៗ រួមមានជាអាទិ៍៖<br>១. **បុគ្គលិក PMU នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត** រួមទាំងទីប្រឹក្សាការអនុវត្តគម្រោង និងមន្ត្រីបរិស្ថាន និងសង្គមរបស់ MRD។ ពិនិត្យចំណេះដឹង និងបទពិសោធន៍ ESF ដែលនឹងត្រូវអនុវត្តយូរៗម្តង (យ៉ាងហោចម្តងក្នុងមួយឆ្នាំ) ដើម្បីដោះស្រាយចន្លោះខ្វះខាតចំណេះដឹង ESF ដែលនៅសល់ឲ្យបានទាន់ពេលវេលា តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល ESF ឡើងវិញដដែលៗ និងកម្រិតខ្ពស់ជាងមុន។ ប្រធានបទបណ្តុះបណ្តាលរួមមានតម្រូវការសំខាន់ៗរបស់ ESF របស់ធនាគារពិភពលោក, លក្ខខណ្ឌសំខាន់ៗមានចែងនៅក្នុង ESMF, RPF, IPPF, LMP, SEP, ESHS រួមទាំង OSH, SEA, SH, VAC, STI ដែលរួមមានមេរោគអេដស៍, កូវីដ១៩, GRM របស់គម្រោង, និងមេរៀនដែលទទួលបានពីគម្រោងស្តារ/សាងសង់ផ្លូវថ្នល់ដែលស្រដៀងគ្នានេះ។<br><br>២. **ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត** ប្រធានបទបណ្តុះបណ្តាលគ្របដណ្តប់លើលក្ខខណ្ឌសំខាន់នៃ ESF របស់ធនាគារពិភពលោក, តម្រូវការសំខាន់ៗដែលមានចែងនៅក្នុង ESMF (រួមមាន RPF, IPPF, LMP), SEP, ESHS, ក៏ដូចជា OSH, SEA, SH, VAC, STI ដែលរួមមានមេរោគអេដស៍, កូវីដ១៩, GRM របស់គម្រោង។ | មួយខែបន្ទាប់ពីគម្រោងចូលជាធរមាន<br><br>យ៉ាងហោចមួយខែមុនការចាប់ផ្តើមការងារសំណង់<br><br>យ៉ាងហោចមួយខែមុនការចាប់ផ្តើមការងារសំណង់<br><br>យ៉ាងហោចមួយខែមុនការចាប់ផ្តើមការងារសំណង់ និងពេញមួយវដ្តគម្រោង និងរយៈពេលថែទាំផ្លូវ | ទីប្រឹក្សា E&S ធ្វើការដោយ PMU (ដោយមានការគាំទ្រពីខាងក្រៅពីធនាគារពិភពលោក)<br><br>ទីប្រឹក្សា E&S ធ្វើការដោយ PMU (ដោយមានការគាំទ្រពីខាងក្រៅពីធនាគារពិភពលោក)<br><br>SEO របស់ MRD |

| | | | |
|---|---|---|---|
| | សៀវភៅណែនាំ ESMP ត្រូវបានអភិវឌ្ឍឡើង និងបានអនុវត្តក្រោមគម្រោង KH-SEADRM បច្ចុប្បន្ន រួមទាំងការអនុវត្តល្អៗស្តីពីការតាមដាន និងការរាយការណ៍ពីគម្រោងផ្លូវថ្នល់ផ្សេងទៀត ដែលបានបញ្ចូលទៅក្នុងការបណ្តុះបណ្តាលសម្រាប់ក្រុមហ៊ុនម៉ៅការ។<br><br>**ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត** ទទួលខុសត្រូវក្នុងការផ្តល់វគ្គបណ្តុះបណ្តាលដល់កម្មកររបស់ខ្លួនទាំងអស់អំពី ESHS, ក្រមសីលធម៌ពាក់ព័ន្ធនឹង SEA, SH, VAC និង GRM សម្រាប់កម្មករ ដែលជាផ្នែកមួយនៃ C-ESMP និង C-LMP ។<br><br>៣. **សហគមន៍** សុវត្ថិភាពចរាចរណ៍ផ្លូវគោក, SEA, SH, VAC, STI ដែលរួមមានមេរោគអេដស៍, កូវីដ១៩, GRM របស់គម្រោង។ | | PMU<br>ក្រុមហ៊ុនម៉ៅការ |